# រដ្ឋាភិបាលរដ្ឋ លោក Deveal Patrick បានប្រកាសអំពីការអប់រំមួយដើម្បីការពារជម្ងឺ EEE និង West Nile Virus។

Patrick Administration Launches Major Public Awareness Campaign
to Prevent EEE and West Nile Virus
DPH release 2 News Public Services Announcements, resources for Local

ក្រសួងសាធារណៈសុខាភិបាលនៃរដ្ឋម៉ាស្សាឈូសេត បានប្រកាសកាលពីថ្ងៃសុក្រកន្លងមកនេះ ដើម្បីឲ្យសាធារណៈជនជ្រាបអំពីរោគផ្សេងៗ ដែលទាក់ទងទៅនឹងមុសខាំ រួមទាំងរោគ Eastern Equine Encephalitis (EEE) និងរោគ West Nile Virus។ លោក John Auerbach នាយស្តងការនៃក្រសួងសាធារណៈសុខាភិបាល និងវេជ្ជបណ្ឌិត Alfred Demaria នាយកផ្នែកខាងបង្រ្កាបជម្ងឺឆ្លងនៃក្រសួងសាធារណៈសុខាភិបាលដែរ បានប្រកាសអំពីរោគទាំងនេះនៅមន្ទីរពិសោធន៍ប្រចាំរដ្ឋ នៅ Jamaica Plain ទីក្រុងបុស្តុន ហើយបានជួបជាមួយអ្នកស្រី Kimberly King ដែលមានកូនស្រីអាយុ 5 ឆ្នាំ ស្លាប់ដោយសាររោគ EEE កាលពីឆ្នាំ 2005។

នៅក្នុងការប្រកាសនេះ នាយស្តងការនៃក្រសួងសាធារណៈសុខាភិបាលបានរៀបរាប់អំពីមធ្យោបាយផ្សេងៗ ដែលក្រសួងត្រូវអនុវត្ត ដើម្បីផ្តល់ដំណឹងនិងអប់រំសាធារណៈជន អំពីរោគបណ្តាលមកពីមុសខាំ នៅក្នុងរដូវក្តៅនេះ។ លោកមានប្រសាសន៍ថា វិធីការពារ ជាជំហានមួយដ៏ចម្បងបំផុត នៃវិស័យសាធារណៈសុខាភិបាល។ ក្រសួងនឹងចាត់វិធានការណ៍គ្រប់បែបយ៉ាង ដើម្បីការពារសុខភាពសាធារណៈជន។ លោកមានប្រសាសន៍ទៀតថា សាធារណៈជនអាចកាត់បន្ថយកុំឲ្យឆ្លងរោគ EEE និងរោគ West Nile Virus នេះបានដោយប្រើមធ្យោបាយយ៉ាងងាយបំផុត គឺ ជៀសវាងកុំឲ្យមូសខាំ។

នៅក្នុងរដូវក្តៅនេះ ក្រសួងសាធារណៈសុខាភិបាល នឹងផ្សាយដំណឹងពីរតាមរយៈទូរទស្សន៍នៅតំបន់រដ្ឋម៉ាសាឈូសេត្សខាងកើត ដែលជាតំបន់ធ្លាប់មានមនុស្សកើតរោគទាំងនេះ ច្រើនជាងគេ។ ដំណឹង ឬ PSA នេះ គឺស្តីអំពីមនុស្សពីរនាក់នៅក្នុងរដ្ឋម៉ាស្សាឈូសេត ដែលបានធ្លាក់ខ្លួនឈឺដោយកើតរោគបណ្តាលមកពីមានមុសខាំ។ ជនទីមួយគឺ Derek Ashworth អាយុ 23 ឆ្នាំ ជាអ្នកលេងកីឡា Foot ball នៅទីក្រុង Acushnet ។ បុរសនេះកើតរោគ EEE កាលពីឆ្នាំមុន ហើយបានជាសះស្បើយមកវិញ។ ឯជនរងគ្រោះទីពីរ គឺកុមារី Adreana ជាកូន របស់អ្នកស្រី Kimberly King នៅទីក្រុង Hanson ដែលបានធ្លាក់ខ្លួនឈឺ រហូតដល់ស្លាប់បាត់បង់ជីវិត ដោយសាររោគ EEE កាលពី ឆ្នាំ 2005 ។

ក្រសួងបានផ្តល់ជំនួយជាថវិការចំនួន $300,000 (៣០ ម៉ឺនដុល្លា) ដល់ទីក្រុងនានា ក្នុងរដ្ឋម៉ាស្សាឈូសេត ដើម្បីអប់រំនិងចាត់វិធានការណ៍ការពារសុខភាពសាធារណៈ រួមទាំងការពាររោគ EEE និងរោគ West Nile Virus នេះផងដែរ។ ជាមួយគ្នានេះក្រសួងបានបោះពុម្ភលិខិតជាច្រើនភាសារសំរាប់អប់រំប្រជាជនអំពីរោគទាំងនេះ។

ឆ្នាំមុន ជាឆ្នាំទីបី ដែលរដ្ឋម៉ាស្សាឈូសេតមានរោគ EEE និងរោគ West Nile Virus ច្រើនបន្តរបន្ទាប់គ្នា។ ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ មានមនុស្សចំនួន 13 នាក់ កើតរោគ EEE ហើយក្នុងចំណោមនោះ 6 នាក់បានស្លាប់បាត់បង់ជីវិត។ ក្នុងរយៈពេលជាមួយគ្នានេះ ក៏មានអ្នកកើតរោគ WNV ដែរ ហើយមានម្នាក់ស្លាប់។

លោកវេជ្ជបណ្ឌិត Alfred Demaria នាយកផ្នែកខាងបង្ក្រាបជម្ងឺឆ្លងនៃក្រសួងសាធារណៈសុខាភិបាលរដ្ឋម៉ាស្សាឈូសេត មានប្រសាសន៍ថា ដូច្នេះហើយបានជាការមួយចាំបាច់បំផុតដែលសាធារណៈជនគួរចាត់វិធានការណ៍ គឺគួរធ្វើអ្វីដែលត្រូវធ្វើ ដើម្បីការពារខ្លួនឯងនិងគ្រួសារ ឲ្យជៀសផុតពីរោគនេះ។ មធ្យោបាយទាំងនេះ មានរួមទាំង៖

- ការប្រើថ្នាំសំរាប់លាបកុំឲ្យមូសខាំ ដែលមានជាតិ DEET ឬថ្នាំដែលទីភ្នាក់ងារការពារបរិយាកាស Environment Protection Agency (EPA) បានយល់ព្រមឲ្យប្រើ។
- ជៀសវាងកុំនៅក្រៅផ្ទះយូរពេក ជាពិសេស នៅពេលដែលមានមូសច្រើនៈ មូសច្រើនមាននៅពេលព្រលប់ទល់ព្រលឹម។ ប្រសិនបើលោកអ្នកត្រូវការចាំបាច់នៅក្រៅគួរស្លៀកខោជើងវែងនិងអាវដៃវែង ដើម្បីគ្រប់ឲ្យជិតរាងកាយ។
- សូមប្រើសំទ្បាញ់នៅតាមបង្អួចនិងទ្វា ឬជួសជុលវាំងឲ្យបានជិតល្អ ដើម្បីការពារកុំឲ្យមានមូស ចូលក្នុងផ្ទះបាន។

មធ្យោបាយផ្សេងៗទៀតដែលលោកអ្នកអាចធ្វើបាន គឺ៖

- ចាក់ទឹកដែលមាននៅជុំវិញបរិវេណផ្ទះចោល ដោយផ្កាប់ផើងផ្កា, ឬធុងសំរាប, ដើម្បីកុំឲ្យមានដក់ទឹក។
- ប្រសិនបើមានអាងទឹក (Pool) សូមឧស្សាហ៍លាងសំអាតនិងប្រើជាតិ Chlorine ហើយគ្រប់វាឲ្យជិត នៅពេលណាដែលពុំត្រូវការប្រើប្រាស់។ ម្យ៉ាងទៀត សូមឧស្សាហ៍ពិនិត្យមើលគំរាបនោះកុំឲ្យមានដក់ទឹកផងដែរ។
- ចំពោះទទឹកវិញ សូមបាសំរាម ឬស្លឹកឈើឲ្យអស់ពីវា ដើម្បីកុំឲ្យស្ទះ នាំឲ្យដក់ទឹក។

ខ្ញុំបាទសូមជំរាបថា មេរោគវេះណៃល ជាមេរោគម្យ៉ាងដែលធ្វើឲ្យមនុស្សយើងធ្លាក់ខ្លួនឈឺពីគ្រុនក្តៅ ទៅជាឈឺធ្ងន់ធ្ងរ រហូតដល់រលាកខួរក្បាល ពាក្យអង់គ្លេសហៅថា Encephalitis ឬរលាកស្រោមខួរ ក្បាល ហៅថា Meningitis។  ឯរោគ Eastern Equine Encephalitis (EEE) វិញ គឺធ្វើឲ្យអ្នកជម្ងឺគ្រុនក្តៅ (103 អង្សា), រឹងកញ្ចឹងក, ហើយអស់កម្លាំងល្ហិតល្ហៃ។ អាការៈនេះច្រើនមានក្នុងរយៈពេលពី 3ថ្ងៃ ទៅ 10ថ្ងៃ បន្ទាប់ពីមានមូសដែលមានមេរោគទាំងនេះខាំ។  បន្ទាប់មកវាធ្វើឲ្យអ្នកជម្ងឺហើមខួរក្បាល ហើយឈឺជាទម្ងន់រហូតដល់សម្លប់បាត់ស្មារតី ក្នុងរយៈពេលមួយអាទិត្យបន្ទាប់ពីចាប់ផ្តើមឈឺមក។

ចំពោះពត៌មានបន្ថែមស្តីអំពីវិធីការពាររោគដែលបណ្តាលពីមូសខាំ។ សាធារណៈជនក្នុងរដ្ឋម៉ាស្សាឈូសេត អាចអានវិបសៃរបស់ក្រសួងសាធារណៈសុខាភិបាលប្រចាំរដ្ឋម៉ាស្សាឈូសេត ដែលមានអាសយដ្ឋាន [www.mass.gov/dph](http://www.mass.gov/dph) ឬទូរស័ព្ទទៅក្រសួងដដែល នូវលេខ (617) 983-6800។

*ពត៌មាននេះដកស្រង់និងបកប្រែចេញពីពត៌មាននៃក្រសួងសាធារណៈសុខាភិបាលនៃរដ្ឋម៉ាស្សាឈូសេត ដោយមណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។*